# ចំណាប់ខ្មាំងប៊ីយ៉ានកា- Bi anca

«កុំចូលកៀក! មិនមែនគ្នាយើងទេ! ជាពួកមនុស្ស!»

ខ្ញុំឮសំឡេងពួកគេបន្ទរមកជុំទិស។ ព្រៃមិនមែនជាមិត្តរបស់ខ្ញុំទេជាពិសេសយប់នេះ រងានិងពេញដោយពួកសត្វទីទុយស្រែក ម្រឹគគ្រហឹម ចចកលូមកពីឆ្ងាយ ខណៈដែលពន្លឺព្រះចន្ទរះមកខៀវស្រងាត់ លន្លង់លន្លោច  អ្វីៗទាំងអស់ត្រូវបានបំភ្លេចចោលព្រោះឥឡូវនេះខ្ញុំចង់«រស់»។

អ្វីទាំងអស់ចំពោះមុខ គឺ....

«ដើរ!»

សំឡេងគ្រលរគំហក បង្ខំ ហើយជននេះនៅពីក្រោយខ្ញុំ រុញខ្ញុំទៅមុខយ៉ាងខ្លាំងក្លា ខ្ញុំស្ទើរតែដួលទប់ជំហរវិលវល់ ប៉ុន្តែអាចគ្រប់គ្រងតុល្យភាពឡើងវិញបានយ៉ាងឆាប់រហ័ស ហើយខ្ញុំនៅតែឈរ។ ខ្ញុំមានគម្រោងឈរឱ្យបានយូរតាមដែលខ្ញុំអាចធ្វើបាន ព្រោះពួកគេចង់ឱ្យខ្ញុំលុតជង្គង់ទទួលថា ខ្ញុំនៅក្រោមពួកគេ។

«ខ្ញុំមិនចង់វាយប្រយុទ្ធជាមួយមនុស្សខ្សោយអ៊ីចឹងទេ!»

Gala មេដឹកនាំពិភពខ្មៅដែលខ្ញុំស្គាល់ កំពុងចំអកខ្ញុំ។ យើងមិនធ្លាប់ជាមិត្តនឹងគ្នាទេ ប៉ុន្តែខ្ញុំគិតថាយ៉ាងហោចណាស់យើងត្រូវអត់ឱនគ្នា តែនេះជាការគិតខុស។ ពិភពលោកនេះនឹងជាន់អ្នកខ្សោយ។

នេះជាកោះមួយ ដែលមានទីក្រុងអរូបីបន្សល់នៅ។

ខ្ញុំមិនមានម្ដាយឬឪពុក មិនមានគ្រួសារទេ ខ្ញុំមិនមាននរណាទាំងអស់  វាជាជីវិតដែលខ្ញុំបានរីកចម្រើនឡើងដោយសេរីភាព ព្រោះខ្ញុំមិនដែលមានអ្វីផ្សេងទៀតដើម្បីប្រៀបធៀបឬបុព្វហេតុផ្សេងក្រៅពីខ្លួនឯង។

ខ្ញុំមិនអាចនឹកភ្នកដល់អ្វីដែលមិនធ្លាប់មាននោះទេ សូម្បីភាពកក់ក្ដៅ ក្ដីស្រលាញ់ ការការពារគឺជាអ្វីដែលខ្ញុំមិនទាំងធ្លាប់មានបន្តិចណា ម្ដេចស្រមៃចេញ?

ប្រាប់ហើយពេលដែលខ្ញុំកាន់តែចាស់នោះ ខ្ញុំកាន់តែយល់ច្បាស់ថា របស់ខាងលើមិនមែនកើតមានលើមនុស្សគ្រប់គ្នាទេ។

ក្រឡេកសត្រូវមួយជុំនេះ ខ្ញុំស្គាល់ពួកគេទាំងអស់។ ខ្ញុំស្គាល់ជាងគេម្នាក់ដែលធ្វើជាខែងរ៉ែង ដាក់ខ្ញុំ ឈ្មោះGala។ ម្នាក់នេះក្បាលត្រម៉ោងសក់ក្រហមឆេះ ភ្នែកកាចសាហាវ និងអណ្តាតដ៏វែង សំឡេងគ្រលរ។

ក្បែរនោះ ខ្ញុំក៏ស្គាល់។ Cassius ជាក្មេងប្រុសសក់រួញអង្កាញ់ ដែលធ្លាប់ឱ្យខ្ញុំខ្ចីសៀវភៅពីបណ្ណាល័យរបស់ប៉ាគេ ម្ខាងទៀតខ្ញុំក៏ស្គាល់ គឺនាងWillow ដែលជាមនុស្សនិយាយស្ដីទន់ភ្លន់ ហើយគេនៅឈរទីនេះ ព្រោះGalaគឺជាប្អូនស្រីរបស់នាង ព្រោះនាងស្រលាញ់និងតាមប្អូនស្រីរបស់នាងគ្រប់យ៉ាងមិនថា ទៅកាន់ឋាននរក។ នាងមិនមើលមកស្ថានភាពរបស់ខ្ញុំទេ។

ខ្ញុំស្គាល់ពីរនាក់ទៀតដែរ ប៉ុន្តែខ្ញុំមិនខ្វល់ពីអ្នកណាជាអ្នកណា។ មួយជីវិតនេះ ខ្ញុំដោះស្រាយគ្រប់យ៉ាងដោយខ្លួនខ្ញុំ ហើយនេះមិនមែនជាលើកទីមួយទេដែលខ្ញុំត្រូវគេធ្វើបាប។

យប់នេះ លើសរាល់ដងហើយ! ខ្ញុំអាចមើលឃើញអត្ថន័យនេះ នៅក្នុងភ្នែករបស់ពួកគេ។ ភ្នែកស្រេកឈាមរបស់ពួកគេ។

ប្រេះប្រស់ៗ.....ជាសំឡេងចម្លែកលេចចេញមកពីក្នុងគុម្ពោតព្រៃ។ ពួកគេទាំងអស់គ្នាមានប្រតិកម្មរហ័សនិងបែរក្បាលទៅទិសដៅនោះ។ សំឡេងគ្រហឹមស្រទន់មួយត្រូវបានបន្លឺមកឱ្យយើងឮ គ្មានយើងណាម្នាក់ដឹងថា វាជាសត្វអ្វីឱ្យប្រាកដទេ។

«Gala?» Willow ខ្សឹបតិចៗក្នុងសព្ទភ័យខ្លាច។ ខ្ញុំមិនចង់វិនិច្ឆ័យទេ ព្រោះបើនិយាយសំឡេងខ្ញុំក៏ប្រហែលញ័រដូចគ្នា។

«Shhh» Galaវាយបងនាងផាច់ដូចរាល់ដង។

គ្រឹម!

ម្ដងទៀត សំឡេងគ្រហឹមដដែលលាន់មកតែខ្លាំងជាងមុន ញ៉ាំងមនុស្សគ្រប់គ្នាឈានដើរថយក្រោយ ហើយរំពៃមើលជុំវិញខ្លួន បើកភ្នែកធំៗដោយញាប់ញ័រប្រុងប្រយ័ត្ន។

ចចក? ខ្លាឃ្មុំ? មិនមានខ្លាឃ្មុំណាបង្ហាញវត្តមាននៅជុំវិញទីនេះក្នុងរយៈពេលជាច្រើនឆ្នាំមកហើយ។ ប៉ុន្តែសត្វណាក៏ដោយ ជាមិត្តរបស់ខ្ញុំព្រោះខ្ញុំចង់ឱ្យវាឆីអ្នកទាំងនេះ។

«កុំគិតថារួចខ្លួន! ពេលក្រោយនាងឯង!» Galaស្រែកដាក់ខ្ញុំ ដោយទាញខ្ញុំមកហើយអុកយ៉ាងខ្លាំងជាមួយនឹងស្មារបស់នាង។ បន្សល់ទុកស្នាមជាំ ខ្ញុំដឹងថា ឈឺណាស់! ហើយដឹងទៀតថា នេះនៅតិចជាងអ្វីដែលនាងគ្រោងនឹងធ្វើចំពោះខ្ញុំនៅយប់នេះ។

គេរត់ទៅចោលខ្ញុំអស់ នៅតែម្នាក់ឯង សូម្បីGala។ ខ្ញុំលេបទឹកមាត់ភ័យយ៉ាងខ្លាំង ដោយសម្លឹងទៅទិសដៅដែលសំឡេងគ្រហឹមបានលាន់ចេញមក។ គុម្ពោតរង្គោះម្តងទៀត ខ្ញុំមិនហ៊ានកម្រើកព្រោះរត់មិនបានទេ គង់តែផ្កាប់មុខ ដៃខ្ញុំជាប់ចំណងទៅក្រោយយ៉ាងមាំហើយ ខ្ញុំនៅជិតនឹងគុម្ពោតនោះ បានត្រឹមឈានខ្ញុំដើរថយក្រោយមួយជំហាន  បន្ទាប់មកខ្ញុំទប់ការរន្ធត់ ឈានមួយជំហានទៀត។

រំពេចនោះគុម្ពោតបានបើកចំហ លេចចេញរូបរាងឈរ ធំ ខ្មៅងងឹតដែលស្ទើរតែលាយបន្លំចូលជាមួយភាពងងឹតជុំវិញគេ។

ពន្លឺព្រះចន្ទកំពុងបំភ្លឺតែផ្នែកមួយនៃមុខរបស់ជននេះ ជាផ្នែកដែលមានស្លាកស្នាមជ្រៅដែលមើលទៅដូចជាដំបៅបានជាសះស្បើយតាំងពីយូរយារណាស់មកហើយ។

«ត្រូវការជំនួយ?»

«ខ្ញុំ...» ខ្ញុំមិនអាចបញ្ចប់ប្រយោគ ជាមួយនឹងគំនិតដែលស្រឡាំងកាំង ភាំង។

«នរណា?»

«អ្នកមកសង្គ្រោះ!» ថាហើយ ជនងងឹតខ្ពស់និងធំដើរមករកខ្ញុំ។

ខ្ញុំសង្កេតគេដោយមិនព្រិចភ្នែក។ គេអាចជាមនុស្សចចកបើតាមសំឡេងគ្រហឹមដែលពួកនោះរត់បែកខ្ញែក តែមិនឃើញចង្កូមនិងក្រចកសម្រាប់ហែកឆីខ្ញុំនៅឡើយ។

ដោយសម្លឹងមកខ្ញុំត្រង់ ស្ទើរតែមានអារម្មណ៍ថា ចចកនេះកំពុងព្យាយាមលួចហិតក្លិនរបស់ខ្ញុំជាទម្លាប់មុននឹងហែកឆី។ ខ្ញុំចង់រត់ ប៉ុន្តែខ្ញុំទៅមិនរួចទេ។

ខ្ញុំថែមទាំងមិនដឹងថានឹងមានដំណោះស្រាយរបៀបណាដែរ ព្រោះមិនទាំងដឹងផងថា គេនេះជានរណា ខ្ញុំមិនដែលឃើញគេពីមុនមកទេ។ នោះមានន័យថា គេមិនបានរស់នៅលើកោះនេះ។

លុះមកជិត សាច់ដុំដ៏ធំបានពន្លយចេញមក សូម្បីតែនៅក្នុងភាពងងឹតក៏ដោយ។ ភ្នែកទាំងគូមានពណ៌បៃតងខ្ចី ហាក់ដូចជាមានបង្កប់ព្រះអាទិត្យតូចៗចែងចាំងពីខាងក្នុងប្រស្រី។

«ខ្ញុំមិនត្រូវការជំនួយទេ» ខ្ញុំនិយាយដោយចចេស សង្ឃឹមថាគេមិនបន្តរុលចូលមក។

«ប្រាកដឬអត់?» គេសួរដោយផ្អៀងក្បាលទៅម្ខាងមើលមកខ្ញុំកាន់តែជិត ស្និទ្ធស្នាលជាងមុន ខណៈភ្នែកបៃតងសម្លឹងមកខ្ញុំដូចជា បង្អែម។

«កុំចូលមក សុំត្រឹម ខ្ញុំបានត្រលប់ទៅក្រុងវិញ»

«រស់នៅក្រុងនោះ?»

«ចាស៎»

បិសាចព្រៃ នាងGalaនិងហ្វូងចចកសេនារបស់នាងបានបាត់ទៅហើយ ប៉ុន្តែនេះមិនមានន័យថាខ្ញុំមានសុវត្ថិភាពទេ។ បុរសនេះគឺជាប្រភេទគ្រោះថ្នាក់មួយផ្សេងទៀតជា ការគំរាមកំហែងមួយថ្មី។

ខ្ញុំបន្តដើរថយក្រោយដោយញាប់ញ័រ ខណៈជននេះងក់ក្បាលញញឹមដាក់ខ្ញុំ។

ឥឡូវនេះខ្ញុំអាចមើលឃើញស្នាមលើមុខរបស់គេកាន់តែច្បាស់។ ការចង់ដឹងចង់ឃើញបានសន្ធប់មកលើខ្ញុំ។ ខ្ញុំចង់ចូលទៅជិតគេទៅវិញ មើលឱ្យជិត ប៉ុន្តែខ្ញុំមិនហ៊ានបន្ថែមរយៈចម្ងាយសុវត្ថិភាពដែលនៅចន្លោះពួកយើងទេ។

រឿងស្នាមរបួសនេះនៅតែធ្វើឱ្យមានការភ្ញាក់ផ្អើល។ ខ្ញុំមិនដែលឃើញអ្នកណាមានមុខបែបនេះទេ។ ទោះជាយ៉ាងណា វាហាក់ដូចជាមិនធ្វើឱ្យសម្រស់គេធ្លាក់ចុះឡើយ។ តាមពិត....កាន់តែទាក់ទាញ។ គេខ្លាំង......និងខ្លាំងឡើងៗ ពេលឃើញច្បាស់។

ជាថ្មីម្តងទៀត ខ្ញុំមានអារម្មណ៍ថាមានក្លិនក្រអូបពេញរន្ធច្រមុះរបស់ខ្ញុំក្លិនព្រៃ ក្លិនផែនដីនិងធម្មជាតិ។ ជននេះធុំក្លិនដូចព្រៃឈើជ្រៅៗ ជាកន្លែងពេញដោយពួកសត្វសាហាវៗនិងមានគ្រោះថ្នាក់ជាងអ្វីដែលខ្ញុំធ្លាប់ចួបប្រទះពីមុនមក។ គេស្រាយដៃខ្ញុំដោយបង្ខំ។ ដំបូងខ្ញុំស្រែក ក្រោយមកខ្ញុំសំងំ។

«ស្រាយហើយ!»

គេចាំបាច់ប្រាប់ បើខ្ញុំលើកដៃបានហើយហ្នឹង?

ចុះហេតុអ្វីបានជាពេលនេះ ខ្ញុំនៅតែទន់ជើងមិនអាចរត់ចេញ? អ្វីពិតប្រាកដដែលធ្វើឱ្យខ្ញុំជាប់គាំងនៅកន្លែងនេះ ចាំឱ្យចន្ទរះខ្ពស់បន្តិច គេនឹងចេញចង្កូមមកហែកនិងលេបត្របាក់ខ្ញុំ?

គេនៅកៀកណាស់ឥឡូវនេះ ច្រមុះយើងជិតប៉ះហើយ។ ខ្ញុំអាចមានអារម្មណ៍ថា ដង្ហើមក្ដៅៗរបស់គេជះលើបបូរមាត់របស់ខ្ញុំ។ វាកំពុងហុយមកលើខ្ញុំ ល្បួងខ្ញុំឱ្យធ្វើ...អ្វីមួយ។ ប៉ុន្តែអ្វី? ខ្ញុំមិនហ៊ានធ្វើអ្វីមួយនៃការរំជើបរំជួលដែលលក់ប់ជ្រៅក្នុងប្រាណបានកំពុងលេចចេញសេចក្ដីប្រាថ្នានោះទេ។

ដោយប្រើសតិអារម្មណ៍យ៉ាងពិបាក ខ្ញុំថយក្រោយរកផ្លូវ បានចាកចេញ។ ជាសម្ងាត់ ខ្ញុំគ្រប់គ្រងដើម្បីប្រឆាំងនឹងវេទមន្តស្នេហ៍ដែលសន្ធប់ពីចំហាយដង្ហើមជនមនុស្សមិនចំមនុស្សនេះ។

គេញញឹមដូចដឹងចំណុចខ្សោយខ្ញុំ!

«ត្រលប់ទៅផ្ទះវិញទៅ មនុស្សល្អ!» គេរអ៊ូដោយស្រទន់ ដែលស្ដាប់ទៅដូចជាការសើចចំអកឱ្យបេះដូងខ្ញុំ។

មានអារម្មណ៍ថាក្លាហានជាងមុនព្រោះគេមិនធ្វើអ្វីខ្ញុំ។ ប្រហែលជាស្មានខុស គេអាចជាអ្នកផ្លាស់ទីលំនៅពីទីក្រុងផ្សេងទៀត។

«ហ្នឹងហើយ យប់ជ្រៅហើយ!» ខ្ញុំតបជំនួសពាក្យអរគុណរួចបង្វិលខ្លួនរត់ត្រលប់ទៅទីក្រុងវិញ ឆ្លងកាត់ផ្លូវលំដែលគេវាយដំចាប់ចងនាំខ្លួនខ្ញុំទៅកណ្ដាលព្រៃ។ ខ្ញុំរត់រហូតដល់ដកដង្ហើមតឹងទាំងភ័យព្រោះស្នាមញញឹមត្រជាក់ៗរបស់បុរសនៅតាមលងអារម្មណ៍ ទោះណាជាខ្ញុំលែងឃើញស្រមោលគេទៀត។

## អ្នកសង្គ្រោះ អេដមុន- Edmund

យប់នេះ ខ្ញុំដើរផែកមើលក្នុងព្រៃព្រោះសម្រាប់ខ្ញុំ នេះជាពេលវេលាកាល យុគដែលជម្លោះរវាងពួកអ្នកប្ដូររូបនិងបិសាចជញ្ជក់ឈាម ត្រលប់មមកមានលើផែនដីវិញហើយ។ នេះជាការសរសេរប្រវត្តិសាស្ត្រថ្មីនៃអម្បូរដ៏ចំណាស់របស់យើង មិនថាយ៉ាងណា មុននិងក្រោយ សង្គ្រាមនេះនៅតែបន្តកើតមាន។

ពេលដែលខ្ញុំបានចួបនិងជួយសង្គ្រោះមនុស្សស្រីម្នាក់នោះ ចិត្តរបស់ខ្ញុំបានផុសរូបរបស់នាងនិងរបៀបដែលនាងកំពុងញាប់ញ័រនៅចំពោះមុខខ្ញុំ។ នាងល្អិត ភ័យខ្លាចតែព្យាយាមហាក់ដូចជាក្លាហានណាស់។ ចង់តែគ្រញិចឱ្យស្រែកម្ដង។

«អេដមុន» កាណូ ស្រែកហៅខ្ញុំ ហើយរូបភាពរបស់ស្រីមាត់រឹងក៏រលុបបាត់ពីអារម្មណ៍នេះជា

បណ្តោះអាសន្នសិនដែរ។

«គ្នាយើងសឹងរំលើងទីក្រុងទាំងមូលហើយ រកមិនឃើញអណ្តូងនោះសោះ!»

ខ្ញុំដឹងថា គេកំពុងនិយាយពីអ្វីមួយដែលសំខាន់ តែខ្ញុំនៅតែអនុញ្ញាតឱ្យខ្លួនឯងគិតមួយភ្លែតទៀត មុនកូនចៅខ្ញុំដើរមកដល់។ ប្រហែលជាមនុស្សស្រីនោះ អាចជួយយើង គ្រាន់តែក្រឡេកក៏ឃើញដែរ ថានាងមិនមែនជាអម្បូរអ្នកបន្តវេនទេ។ នារីនេះមិនមែនចចក ក៏មិនមែនបិសាចដូចពួកយើង ប៉ុន្តែ...តើនាងកំពុងធ្វើអ្វីនៅទីក្រុងចាស់នេះ? នាងម៉េចមិនខ្លាចពួកគេនឹងសម្លាប់នាងជាមួយចង្កូមមុតដែលគ្មានមេត្តា?

«អត់ធ្មត់» ខ្ញុំប្រាប់កាណូព្រោះគេចូលមកដល់ហើយ។

«នេះមិនមែនមានន័យថា ចចាមអារ៉ាមពីអណ្តូងនោះមិនពិតនោះទេ! គ្រាន់តែមានពួកផ្សេងលាក់វាពីយើង! លាក់បានល្អសិនចុះ!» ខ្ញុំនិយាយបន្ថែមបែបនេះខណៈកាណូមានទឹកមុខហត់និងស្រងាកចិត្ត។

ពួកយើង អម្បូរអ្នកជញ្ជក់ឈាម យើងពិតជាត្រូវការប្រភពថាមពលពីអណ្តូងនោះដើម្បីនឹងអាច«ឈប់ផឹកឈាមមនុស្ស!»ហើយពួកមនុស្សានិងមានសុវត្ថិភាព។

យើងមិនអាចទ្រទ្រង់ខ្លួនយើងដោយប្រើឈាមសត្វតែមួយមុខឡើយ វាមិនមានសារធាតុចិញ្ចឹមគ្រប់គ្រាន់បានជាយើងត្រូវការមនុស្ស! សេចក្តីត្រូវការនេះនៅតែបន្ថែមឡើងច្រើនទៀតដោយសារទាយាទរបស់ពួកយើង។ ហើយច្រើនទៀត ដែលឱកាសគ្រោះថ្នាក់ធ្ងន់មនុស្សក្នុងផែនដីត្រូវប្រឈម។

ទោះយ៉ាងណាក៏ដោយ យើងមិនមែនជាក្រុមតែមួយ កំពុងតែស្វែងរកអណ្តូងថាមពលនោះទេ។ ពួកគេខ្លះក៏ត្រូវការវា អម្បូរខ្លះចង់លាក់អណ្តូងព្រោះចង់ឱ្យយើងនិងប៉ូលិសប៉ះគ្នាដើម្បីបញ្ចប់អម្បូរពួកយើង។

រឿងព្រេងនិទាន បានក្លាយជាជំនឿយ៉ាងមាំតជំនាន់មកថា អ្នកណាផឹកទឹកអណ្តូងពាន់ឆ្នាំនោះនឹងមានកម្លាំងឡើងវិញភ្លាម ជាកម្លាំងមហាសាល ហើយវាអនុវត្តបានចំពោះតែតំណរបិសាចជញ្ជក់ឈាមប៉ុណ្ណោះនិងសត្វពិសេសមួយចំនួនដែលមានរាងជាមនុស្សតែប៉ុណ្ណោះ។

ដូច្នេះ គ្មានអ្វីចម្លែកទេដែលក្រុមពួកអ្នកបន្តអម្បូរបឺតឈាមទាំងឡាយ បានស៊ូរាប់ជំនាន់តាមរកអណ្តូងនោះ។

កំណត់ត្រាបុព្វបុរសយើងសរសេរថា អណ្តូងមានពិត ហើយធ្លាប់មានអ្នកដែលផឹកគង្គាពីអណ្តូងចាស់ឈ្មោះថា Salubrity នោះ គេមិនអាចលាក់បាំងភាពកំពូលខាងរាងកាយនិងបញ្ញាថាមពលទេ។

កាណូក្រពាត់ដៃចាំបញ្ជា។ ខ្ញុំប្រាប់គេៈ

«យើងនឹងស្នាក់នៅទីនេះបន្ត ជជីករកឱ្យបានល្អគ្រប់ទីកន្លែង!»

«ពួកយើងនឹងរំលើងគ្រប់ច្រកល្ហក!» Kanoធានាធ្វើឱ្យខ្ញុំដោយងក់ក្បាល។

«ខ្ញុំដឹង» ហើយចុចដៃទៅស្មា ច្របាច់គេក្នុងលក្ខណៈទុកចិត្តយុបឃិតគ្នាស្អិតរមួត។ ស្លាកស្នាមលើមុខរបស់ខ្ញុំ គឺគ្រប់គ្រាន់បញ្ជាក់ពីការប្តូរស្លាប់រស់រវាងពួកយើង។

ជាសំណាងល្អ ខ្ញុំមានKanoនៅក្បែរខ្ញុំ ជីវិតខ្ញុំនៅ តែដល់ឥឡូវសម្លាកមួយនេះនឹងមិនបាត់ទៅណាឡើយ។ ប្រហែលជាប្រសើរដឹងដែលខ្ញុំត្រូវការការរំឭកមួយថា កុំប្រញាប់ប្រញាល់ ទុកចិត្តអ្នករាល់គ្នាដែលយើងមើលទៅថា«មិនអី»។ វាជាមេរៀនមួយ ដែលខ្ញុំបានចំណាយអស់ច្រើនណាស់លើសពីសម្លាកមួយនេះ។

«តស់!»

ការងារបន្ទាប់នេះ ពីរនាក់យើងឆ្ពោះទៅរកក្រុមតូចមួយដែលនៅរង់ចាំប្រមូលផ្តុំគ្នាជុំវិញតុឈើធំវែង។ ខ្លះកំពុងជក់បារី អ្នកផ្សេងទៀតអង្គុយនៅស្ងៀមមួយហ្មង។

សម្រាប់ខ្ញុំ ខ្ញុំដឹងថា ពួកគេទាំងអស់នេះមិនសូវមានភាពអត់ធ្មត់ខ្ពស់ទេ។ ខ្ញុំអាចធុំក្លិនស្រានិងផ្សែងនៃភ្លើងកំហឹង វិលវល់នៅលើអាកាស ជុំវិញបន្ទប់នេះ។

ណ្ហើយ! ពួកយើងកើតមកមានជំងឺស្រេកឃ្លាននិងក្រអូបឈាមមនុស្ស ពួកយើងពុំមែនជាសុភាពបុរសទេ។ ខ្ញុំខ្លួនឯងនេះក៏បានឆ្លងកាត់ការលត់ដំណាស់ ទម្រាំចេះអត់ធ្មត់ខ្លះនិងបានក្លាយជាមេក្រុមត្រួតពីលើពួកគេអស់ទាំងនេះ។

ពេលនេះ យើងកំពុងតស៊ូនឹងអារម្មណ៍អស់សង្ឃឹម។ ពួកគេនេះទទួលអារម្មណ៍ថា យើងជិតដល់កម្រិតផុតពូជហើយ ព្រោះមនុស្សលោកមិនព្រមឱ្យក្រុមបិសាចជញ្ជក់ឈាមបន្តរស់នៅបំផ្លាញឬគំរាមកំហែងសុវត្ថិភាពពួកគេទេ។

អម្បូរជាច្រើនស្រដៀងនឹងយើង បាននឹងកំពុងបាត់ខ្លួនបន្តិចម្តងៗពីផ្ទៃផែនដី ដោយសារហេតុផលជាច្រើន។ មួយក្នុងចំណោមនោះគឺយើង មិនមានបិសាចជញ្ជក់ឈាមស្រ្តីច្រើនគ្រប់នឹងបន្តពូជទេ។

មានបុរសជាច្រើនក្នុងចំណោមពួកយើងមានស្នេហាពិត ហើយមិនព្រមបង្ខំស្រ្តីឱ្យក្លាយជាបិសាចជញ្ជក់ឈាមទេ ព្រោះជាជីវិតដ៏លំបាកមួយ លើសពីអ្វីដែលអ្នករាល់គ្នានឹកស្មានដល់។

ក្នុងនាមជាអម្បូរបិសាចជញ្ជក់ឈាម...យើងមិនអាចរួមរស់ជាមួយអ្នកណាម្នាក់ជាគ្រួសារបានទេដរាបណាគេមិនជញ្ជក់ឈាមដែរ ប៉ុន្តែត្រឹមរួមភេទនាងហើយបោះបង់ចោលគឺធ្វើបាន។

ដូចគ្នានេះ ការសន្ទនាដែលខ្ញុំធ្លាប់មានច្រើនដងជាមួយKano ស្ដេចបិសាចគឺរឹតតែតឹងរឹងជាងបិសាចធម្មតា ព្រោះគេត្រូវតែចាប់ដៃគូជាមួយព្រះនាងដែលមានធាតុបិសាចជញ្ជក់ឈាម ប៉ុន្តែខ្ញុំមិនបានគិតថា នឹងអាចជួបអ្នកដែលខ្ញុំមាននិស្ស័យស្នេហ៍ ហើយជាបិសាចដូចគ្នាទេ។

ពេលខ្ញុំឈានចូលទៅជិត ក្រុមតូចកេះគ្នាក្រោកឈរបង្ហាញការគោរព។

ខ្ញុំងក់ក្បាលយ៉ាងលឿន ជាសញ្ញាឱ្យពួកគេអង្គុយចុះ។

ពួកគេធ្វើតាម! ខ្ញុំអាចមើលឃើញភាពអត់ធ្មត់នៅក្នុងភ្នែករបស់ពួកគេ យ៉ាងតឹងតែង។

ខ្ញុំត្រូវការរំឭកពួកគេយ៉ាងឆាប់ថា៖

«យើងត្រូវតែធ្វើអ្វីៗដោយប្រុងប្រយ័ត្ន»

ទោះបីជាខ្ញុំប្រាកដថាពួកគេទាំងអស់គ្នាដឹងរឿងនេះក៏ដោយតែខ្ញុំចាំបាច់ត្រូវបង្គាកំហឹងពួកគេ៖

«ដូច្នេះ យើងនឹងបំបែកទៅជាពីរៗនាក់ក្នុងមួយក្រុមកុំឱ្យគេភ្ញាក់ផ្អើល! យើងមានដប់ពីរនាក់មានន័យថាប្រាំមួយក្រុម»

ខ្ញុំរង់ចាំមើលថាប្រតិកម្មពួកគេ គ្មានទាំងអស់។ ដូច្នេះខ្ញុំបន្ត៖

«យើងត្រូវស្រូតរូតស្វែងរកអណ្ដូងនោះ! ខ្ញុំមានអារម្មណ៍ថា ដូចជាយើងកំពុងស្វែងរកម្ជុលនៅក្នុងសមុទ្រ ដែលលាក់នៅក្រោមស្រទាប់ជាច្រើននៃស្រទាប់ផែនដី។ ច្រើនសតវត្សមកនេះ អណ្ដូងទឹកវេទមន្តអាចនឹងធំធាត់ក្លាយជាស្ទឹង ឬបឹង ស្រះអ្វីមួយ តែក៏អាចរលុបកប់ស្ងួតរីងបាត់ដែរ! តែ....ដោយសារវាជាជីវិតនៃអម្បូររបស់យើង យើងមិនអាចអស់សង្ឃឹមនោះទេ! វាគ្រាន់តែត្រូវការការ

ខិតខំនិងកម្លាំងចិត្ត! ធម្មជាតិដាក់វិញ្ញាសារនេះមក ប្រាកដជាមានចម្លើយឱ្យយើង! ពុំនោះទេ យើងនឹងរើសវិធីរបស់យើង!»

ខ្ញុំអាចឃើញសម្គាល់ឃើញថា អ្នករាល់គ្នាស្ដាប់ហើយក៏មានអារម្មណ៍ព្រឺសៗនៃសេចក្ដីសង្ឃឹម។ អណ្ដូងនោះមិនមែនសម្រាប់តែជំនាន់យើងទេ ក៏សម្រាប់អ្នកជាន់ក្រោយ យើងត្រូវការបន្សល់ទុកនូវសន្តិភាពក្នុងលោកនេះ។

បរាជ័យមិនមែនជាជម្រើសឡើយ។

«អេដមុន! យើងចាប់ផ្ដើមនៅពេលណា?» Halim សួរឡើងម្ដង។

ខ្ញុំប្រាប់ទៅពួកគេភ្លាម៖

«គិតថា ឥឡូវ! ហើយល្អបំផុតដែលយើងចេញដំណើរការស្វែងរកនៅពេលយប់»

«ប៉ុន្តែ.....ងងឹត!»

ជាការពិតណាស់ អម្បូរយើងមិនអាចមើលឃើញពេលយប់ច្បាស់ដូចពេលថ្ងៃទេ ប៉ុន្តែក៏ជាគ្រោះថ្នាក់សម្រាប់យើងដែលចេញពេលថ្ងៃហើយត្រូវបានប៉ូលិសឃើញ។

«ខ្ញុំមិនចង់ឱ្យពួកយើងឬប៉ូលិសប៉ះគ្នាទេ!»

ថាចប់ ខ្ញុំដើរត្រលប់ទៅតង់របស់ខ្ញុំវិញ ទោះណាជាតឹងតែងដែលឃើញពួកគេរារែក។ ទីនេះផ្ដល់នូវភាពឯកជនតិចតួចមែន ប៉ុន្តែខ្ញុំអាចរក្សាគម្លាតពីសម្ពាធ ឆ្លៀតមកបន្តគិតអំពីលទ្ធភាពដែលអណ្ដូងមិននៅទីនោះ។ ពេលនេះ ម៉ោងនេះគឺជាមធ្យោបាយចុងក្រោយរបស់យើងក្នុងការរក្សាទុកអម្បូរនិងត្រកូលរបស់យើងលើផែនដី ប្រសិនបើយើងមិនអាចស្វែងរកអ្វីដែលយើងចង់បានទេនោះ យើងនឹងត្រូវជាន់ឈ្លីដោយពេលវេលា ហើយទុកឱ្យរលួយខូចដូចអម្បូរដើមដទៃដែរ។

គំនិតនេះបណ្ដាលឱ្យខ្ញុំញាប់ញ័រក្នុងចិត្តរាល់ពេលខ្ញុំបិទភ្នែក។

ខ្ញុំនឹងមិនដេកទេ ពិសេសចាប់តាំងពីទទួលនាទីនេះ ជាមេបិសាច។ ទោះបីជារាងកាយរបស់ខ្ញុំកំពុងអង្វរខ្ញុំក៏ដោយ ក៏ខ្ញុំមានសម្ពាយធ្ងន់ពេកលើទ្រូង។

រូបកាយរបស់យើង ទោះជាពេលនេះអាចទប់ទល់នឹងកាំរស្មីព្រះអាទិត្យបានក៏ដោយ ក៏មិនត្រូវបានបង្កើតឡើងសម្រាប់ទប់ទល់បែបនេះយូរនោះដែរ យើងគ្រាន់តែអាចផ្សាំនិងស៊ូទ្រាំជាមួយពន្លឺយូរជាងអម្បូរដទៃ តែមិនមែនរហូតតទៅទេ។ យើងនៅតែមិនមែនជាមនុស្សពិត។

# ក្លាយជារបស់គេ-ប៊ីយ៉ានកា

ភាពងងឹតឈានមកគំរាមកំហែងលេបព្រលឹងនិងឆន្ទៈរបស់ខ្ញុំទៀតហើយ។ ខ្ញុំដឹងថា គួរតែត្រលប់ទៅទីក្រុងវិញ វាមិនមែនជាកន្លែងសុវត្ថិភាពទេនៅ ក្នុងព្រៃកណ្តាលយប់។

ពួកនាង Galaអាចព្យាយាមវាយប្រហារខ្ញុំម្តងទៀត ហើយប្រុសមានមុខសម្លាកនោះ នឹងមិនលេចមកជាដដែលៗសង្គ្រោះខ្ញុំទេ។

ខ្ញុំចាំបាននូវថ្ម ដែលខ្ញុំកាន់ក្នុងហោប៉ៅអាវរងា។ ធំល្មមនឹងធ្វើឱ្យរបួសបានប្រសិនបើខ្ញុំចោលទៅចំកន្លែង។ អាវុធនេះមិនខ្លាំងទេ ប៉ុន្តែជួយបានសម្រាប់ខ្ញុំបន្តដំណើរឆ្លងកាត់យប់ងងឹត។

មានសំឡេងចម្លែក លាន់មកម្តងម្កាល នៅកន្លែងណាមួយនៅជុំវិញខ្ញុំ។ ដោយព្យាយាមធ្វើពើមិនយកចិត្តទុកដាក់ច្រើនចំពោះវា ខ្ញុំបន្តស្វែងរកផ្លូវចេញ ផ្លូវថ្មីពីកូនព្រៃដែលនឹងនាំខ្ញុំទៅកន្លែងដែលខ្ញុំត្រូវទៅ។

ខ្ញុំមិនទាន់ដឹងថាវានៅឯណានៅឡើយទេ។

ខ្ញុំនៅតែត្រូវពុះពារបន្ត។ មានអ្វីមួយ នាំខ្ញុំចេញពីទីក្រុងនិងឆ្ពោះទៅកាន់ទីរហោស្ថាន ទោះបីជាខ្ញុំមិនដឹងថាអ្វីនោះជាអ្វីក៏ដោយ។ ខ្ញុំដឹងថា វាមានគ្រោះថ្នាក់ក្នុងការធ្វើតាមសភាវគតិ ព្រោះធាតុពិតខ្ញុំដឹងរឿងអម្បូរមនុស្សបុរាណ មនុស្សបិសាចនិងមនុស្សចចក ខ្ញុំមិនមែនជាអ្នកបន្តវេនក្នុងចំណោមពួកគេទេ។ ខ្ញុំគ្មានមហិទ្ធិឫទ្ធិឡើយ។

ខ្ញុំមិនមែនជាម្នាក់ក្នុងចំណោមពួកគេទេ ខ្ញុំមិនស៊ីសង្វាក់នឹងព័ត៌មានលើសពីមនុស្សធម្មតាដែលជាញាណចម្លែកក្នុងខ្លួនរបស់ខ្ញុំទេ...សភាវគតិនិងការជឿជាក់តាំងពីក្មេងមក ខ្ញុំមានទំនាក់ទំនងរវាងចិត្តនិងអម្បូរមនុស្សចម្លែកៗ តែខ្ញុំតែងប្រាប់ខ្លួនឯងថា ខ្ញុំគ្រាន់តែជាមនុស្សធម្មតាម្នាក់តែប៉ុណ្ណោះ។

ព្រោះ!

សំឡេងមែកឈើទង្គិច។

ហើយជើងខ្ញុំក៏ឈប់ភ្លាម។ ដង្ហើមខ្ញុំ លេបចូលយ៉ាងបង្ខំ បេះដូងរបូតសង្វាក់បន្តិច ខ្ញុំមិនហ៊ានបង្វិលឬកម្រើកខ្លួនទេ។ ផ្ទុយទៅវិញ ខ្ញុំផ្ទៀងស្តាប់ ផ្តោតលើការដកដង្ហើមរបស់ខ្ញុំ រួចផ្តោតលើដង្ហើមរបស់អ្នកណាក៏ដោយដែលបង្ហាញខ្លួន។

វិនាទីមានអារម្មណ៍ថា វែងដូចម៉ោង។ ខ្ញុំស្លុប ធ្លាក់ចូលទៅក្នុងភាពងងឹតជុំវិញ ឯអារម្មណ៍ក៏ខ្លាចហួសពីការគិត ប៉ុន្តែរាងកាយទាំងមូលមិនញ័រទេ។ ស្ទើរតែដឹងថា អ្វីមួយដែលខ្ញុំមិនទាន់រកឃើញមានចលនានៅពីក្រោយខ្ញុំ។

ងាកខ្វាច់!

មិនមានអ្វីទាំងអស់។ ខ្ញុំឈរនៅស្ងៀម ហើយអ្វីដែលខ្ញុំគិតថា តាមមកនៅពីក្រោយខ្ញុំ ក៏ធ្វើដូចគ្នា។ រំពឹងថាខ្ញុំនឹងងាកមកប្រឈមមុខនឹងខ្លាឃ្មុំឬចចក ដែលវានឹងហែកវាយប្រហារខ្ញុំដោយធ្មេញនិងចង្កូម ឬមួយអាចជាអ្វីដែលអាក្រក់ជាងនេះទៅទៀត.....បិសាចស្រេកឈាម!

ខ្ញុំឮសំឡេងមួយៈ

«ខ្ញុំធ្វើឱ្យយើងភ័យហើយ មនុស្សផ្អែម!»

ផ្នែកមួយនៃរាងកាយខ្ញុំមិនភ្ញាក់ផ្អើលទាល់តែសោះ ដែលបានឮសំឡេងគេ។ ទោះណាជានៅមិនទាន់ឃើញគេបង្ហាញមុខ ប៉ុន្តែខ្ញុំធូរចិត្តព្រោះដឹងច្បាស់ថាជាគេ អ្នកសង្គ្រោះរបស់ខ្ញុំ។

តើគេតាមការពារខ្ញុំឬបានជួយសង្គ្រោះខ្ញុំពីសត្វសាហាវណាម្តងទៀតអម្បាញ់មិញនេះ?

«លោកមែនទេ?» ខ្ញុំស្ទាបស្ទង់ដោយនិយាយយឺតៗហើយបែរទៅប្រឈមមុខនឹងគេ។

«កំពុងតាមខ្ញុំ?»

ខ្ញុំសួរទាំងបេះដូងសន្ធំក្តៅពេលឃើញរាងកាយដ៏សង្ហារបស់គេ។ ខ្ញុំមិនឱ្យខាតទេ បានព្យាយាមផ្ទង់មើលមុខគេដែលស្រទន់គ្មានភាពអាក្រក់គំរាមអ្វីបន្តិច ទោះណាជាគេនេះ មើលទៅមិនមែនជាមនុស្សសុទ្ធ១០០ភាគរយក្តី។

ព្រះចន្ទពណ៌មាស អណ្តែតមកយ៉ាងធំហើយភ្លឺរន្ទាលនៅពីលើយើង។ ពន្លឺនេះប្រាប់ថា គេអាចជាមនុស្សចចកដែលចេញមកបានតែរាល់ពេលណាខែរះពេញវង់។

«នេះជាប្រទេសដើរហើរសេរី» គេបញ្ជាក់ដោយកែវភ្នែកឌឺដង។

គេមើលខ្ញុំច្បាស់ៗដិត ធ្វើឱ្យខ្ញុំចង់ចាប់ចង្កាគេងាកចេញបង្ខំឱ្យមើលទៅទិសណាផ្សេង ក្រៅពីភ្នែកចាញ់ស្នេហ៍របស់ខ្ញុំ។

បានត្រឹមគិត! ខ្ញុំមិនហ៊ានធ្វើបែបនោះទេ។ ខ្ញុំមិនហ៊ានសូម្បីតែចូលទៅជិតគេទេ តែមាត់ខ្ញុំនៅបន្តជជែកវែកញែកតវ៉ាៈ

«....ប៉ុន្តែ.....ចួបគ្នាដល់ទៅពីរដងក្នុងមួយយប់....គឺ.....ដូចជា!»

«មិនលើសពេកទេ!» គេស្រទន់និយាយមកវិញដោយបោះជំហានឆ្ពោះមកជិតខ្ញុំ «ខ្ញុំគ្រាន់តែចង់ធ្វើឱ្យប្រាកដថា នាងមិនបានដើរវង្វេងក្នុងព្រៃតែម្នាក់ឯង!» គេបន្ថែម។

«ហើយ....ចុះបើខ្ញុំចង់វង្វេង?» ខ្ញុំសួរចចេស «ម៉េចក៏បារម្ភម៉េះ?»

«ស៊ូត!!!» គេគ្រវីក្បាលដាក់ខ្ញុំដោយមិនពេញចិត្ត។

ពេលគេធ្វើបែបនេះ ខ្ញុំសង្កេតឃើញស្លាកស្នាមរបស់ថ្ពាល់គេដែលជ្រៅជាងអ្វីខ្ញុំបានគិត។ កាន់តែគួរឱ្យកត់សម្គាល់ផងដែរ។ ខ្ញុំចង់ប៉ះវាដោយប្រើចុងម្រាមដៃរបស់ខ្ញុំ ដើម្បីមើលថា តើស្នាមអ្វី និងជ្រៅបែបណា?

អូយ! មិនដឹងថាគំនិតឆ្កួតនេះមកពីណាទេ។

ខ្ញុំហាមវា! ព្រោះវាស្ទើរតែបង្ខំខ្ញុំឱ្យចូលទៅជិតគេ...ធ្វើរឿងដែលមិននឹកស្មានដល់ជាមួយគេ ទាំងមិនសមហេតុផលនិងមិនទាំងស្គាល់គេផង។

ខ្ញុំមិនដឹងថាគេជានរណាទេ អាចជាឃាតករសេរី? គេនេះជាអ្នករំលោភសម្លាប់ ឬប្រហែលជាមានកាំភ្លើងឬកាំបិតលាក់នៅក្រោមអាវនោះ?

ហឹម! ការគិតនោះគួរតែធ្វើឱ្យខ្ញុំរត់គេចចេញបន្ទាន់ តែអត់សោះ....កម្លាំងនៃឆន្ទៈដ៏ជ្រាលជ្រៅមួយចំនួនកំពុងរក្សាខ្ញុំនៅបន្តឈរគាំងផ្ទឹងនៅទីនេះ ព្រោះភ្នែករបស់ពួកយើងបានបិទផ្សារជាប់គ្នា។

គេសើចដោយបបូរមាត់បើកចំហចេញធ្មេញលើក្រោម។ ជាស្នាមញញឹមដែលខ្ញុំនឹងត្រូវស្លាប់? ស្នាមញញឹមដើម្បីសម្លាប់ខ្ញុំ?

«ចង់បានអី?» ខ្ញុំសួរតិចៗ

ជំនួសឱ្យការឆ្លើយតប គេដើរមករហូតដល់ច្រមុះយើងជិតប៉ះគ្នា។ ភ្នែកខ្ញុំចង់រសាត់ទៅស្នាមមុខសរបស់គេដើម្បីមើលឱ្យជិត ព្រោះមានអ្វីមួយប្រាប់ខ្ញុំថា មានមនុស្សមិនច្រើនទេដែលហ៊ានឈរជិតបុរសនេះ។ ភ្នែករបស់ពួកយើងកំពុងជក់ចិត្តទាក់ទាមគ្នាដោយរលោមភ្លឺជាងពន្លឺព្រះចន្ទទៅទៀត។

«ក្លាយមកជារបស់ខ្ញុំ នាងនឹងអាចដើរហើរសេរីនិងមិនខ្លាចអ្វីទាំងអស់!»

គេខ្សឹបប្រាប់បែបនេះញ៉ាំងឱ្យរាល់អាតូមនៅក្នុងខ្លួនខ្ញុំញាប់ញ័រ។ ជាការឆ្លើយតបគឺ មិនមានផ្នែកមួយនៃរាងកាយរបស់ខ្ញុំ ដែលមិនប្រតិកម្មរំភើបនឹងសំឡេងចៃចង់របស់គេនោះទេ។

ខ្ញុំមានអារម្មណ៍ថា ខ្ញុំលង់ក្នុងភ្នែកទាំងសងនិងសព្ទសំឡេងនោះ។ មានកម្លាំងដង្ហើមក្តៅៗ ដែលហៀរហូរចេញពីបបូរមាត់របស់គេមកចាក់ឬសក្នុងបេះដូងខ្ញុំ។

ចិត្តខ្ញុំនឹកឃើញរំឭកចុះឡើងៗនូវពាក្យដែលគេទើបនឹងបានប្រើ«ប្រសិនបើក្លាយមកជារបស់ខ្ញុំ!»

ខ្ញុំមិនដែលជាកម្មសិទ្ធិរបស់នរណាម្នាក់ទេ។